# គោលការណ៍ណែនាំ ស្ដីពីការការពារពីការស្រូបផ្សែងបារីដោយអចេតនា ដែលបានរៀបចំលំអិត ដោយក្រុមការងារអនុសញ្ញា ផ្អែកលើការសំរេចចិត្ត FCTC/COP1(15) នៃសន្និសិទភាគីលើកទី១ គោលបំណង កម្មវត្ថុ និងការពិចារណាគន្លឹះ

## គោលបំណង នៃគោលការណ៍ណែនាំ

១. ដើម្បីឱ្យស្របនឹងបញ្ញត្តិផ្សេងៗ នៃអនុសញ្ញាត្រួតពិនិត្យថ្នាំជក់ របស់អង្គការសុខភាពពិភពលោក និងបំណងនៃសន្និសិទភាគី គោលការណ៍ណែនាំនេះ មានគោលបំណងជួយដល់ភាគីទាំងអស់ឱ្យសំរេចបានកាតព្វកិច្ចរបស់ពួកគេចំពោះមាត្រាទី៨។ ពួកគេតាក់តែងឡើងផ្អែកលើទិន្នន័យដែលមានស្រាប់ល្អបំផុត និងបទពិសោធន៍របស់ភាគីផ្សេងៗ ដែលមានវិធានការដ៏មានប្រសិទ្ធិភាពអនុវត្តបានជោគជ័យ ដើម្បីកាត់បន្ថយការស្រូបផ្សែងបារីដោយអចេតនា។

២. សមាសធាតុនៃគោលការណ៍ណែនាំ បានឯកភាពលើអំណះអំណាងជាគោលការណ៍ និងនិយមន័យដែលពាក់ព័ន្ធលើវាក្យស័ព្ទ ក៏ដូចជាបានឯកភាពលើអនុសាសន៍ សំរាប់ឈានទៅសំរេចកាតព្វកិច្ចនៃអនុសញ្ញា ជាទីគាប់ចិត្ត។ លើសពីនេះទៀត គោលការណ៍ណែនាំកំណត់វិធានការចាំបាច់ ដើម្បីសំរេចបានការការពារគ្រោះថ្នាក់នៃការស្រូបផ្សែងបារីដោយអចេតនា។ ភាគីទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់គោលការណ៍ណែនាំ ដោយមិនគ្រាន់តែបំពេញនូវនិតិវិធីច្បាប់នៃអនុសញ្ញាប៉ុណ្ណោះទេ ប៉ុន្តែត្រូវគោរពតាមការអនុវត្តឱ្យមានប្រសិទ្ធិភាពបំផុត ក្នុងការការពារសុខភាពសាធារណៈ។

## កម្មវត្ថុ នៃគោលការណ៍ណែនាំ

៣. គោលការណ៍ណែនាំនេះមានកម្មវត្ថុចំនួន២។ ទី១គឺ ជួយដល់ភាគីទាំងអស់ឱ្យសំរេចបានកាតព្វកិច្ចរបស់ពួកគេចំពោះមាត្រាទី៨ នៃអនុសញ្ញាត្រួតពិនិត្យថ្នាំជក់ របស់អង្គការសុខភាពពិភពលោក។ ក្នុងលក្ខណៈឱ្យស្របនឹងភស្តុតាងវិទ្យាសាស្ត្រ ចំពោះការស្រូបផ្សែងបារីដោយអចេតនា និងការអនុវត្តន៍ត្រឹមត្រូវបំផុតវិធានការគ្មានផ្សែងបារីនៅទូទាំងពិភពលោក ដើម្បីបង្កើតបទដ្ឋានគណនេយ្យភាពខ្ពស់ សំរាប់បំពេញឱ្យសន្ធិសញ្ញា និងជួយដល់ភាគីទាំងអស់ ក្នុងការលើកកំពស់ការទទួលបានបទដ្ឋានសុខភាពខ្ពស់បំផុត។ កម្មវត្ថុទី២ គឺកំណត់សមាសធាតុគន្លឹះ នៃច្បាប់សំខាន់ៗ ដើម្បីការពារមនុស្សពីការស្រូបផ្សែងបារីដោយអចេតនាឱ្យមានប្រសិទ្ធិភាពដែលឆ្លើយតបនឹងមាត្រាទី៨។

**មូលដ្ឋាននៃការពិចារណា**

៤. ការបង្កើតគោលការណ៍ណែនាំនេះត្រូវបានទទួលឥទ្ធិពលដោយការពិចារណាជាមូលដ្ឋានដូចខាងក្រោម :

ក) ភារកិច្ចការពារផ្សែងបារី ផ្នែកខ្លះនៃអត្ថបទក្នុងមាត្រាទី៨ ត្រូវបានចាក់គ្រឹះ ក្នុងមូលដ្ឋាននៃសិទ្ធិមនុស្ស និងសេរីភាព។ ការបង្កគ្រោះថ្នាក់នៃការស្រូបផ្សែងបារីដោយអចេតនា ភារកិច្ចមិនច្បាស់លាស់ចំពោះការស្រូបផ្សែងបារី នៅក្នុងអន្តរសម្ព័ន្ធ សិទ្ធិមានជីវិត និងសិទ្ធិទទួលបានបទដ្ឋានសុខភាពខ្ពស់បំផុត ដូចជាការទទួលស្គាល់នៅក្នុងច្បាប់អន្តរជាតិជាច្រើន (រួមទាំងធម្មនុញ្ញរបស់អង្គការសុខភាពពិភពលោក អនុសញ្ញា ស្ដីពីសិទ្ធិកុមារ អនុសញ្ញា ស្ដីពីការលប់បំបាត់ការរើសអើងគ្រប់រូបភាពប្រឆាំងនឹងស្ត្រី និងអនុសញ្ញា ស្ដីពីសិទ្ធិចូលរួមសេដ្ឋកិច្ច សង្គម និងវប្បធម៌) ការចូលរួមជាផ្លូវការក្នុងក្របខ័ណ្ឌអនុសញ្ញារបស់អង្គការសុខភាពពិភពលោក និងការទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញរបស់ប្រទេសជាច្រើន។

ខ) ភារកិច្ចការពារបុគ្គលគ្រប់រូបពីផ្សែងបារី ឆ្លើយតបកាតព្វកិច្ចរបស់រដ្ឋាភិបាល ដើម្បីអនុម័តច្បាប់ការពារជនគ្រប់រូបប្រឆាំងនឹងសន្ធិសញ្ញា សិទ្ធិជាមូលដ្ឋាន និងសេរីភាពរបស់ពួកគេ។ កាតព្វកិច្ចនេះត្រូវពង្រីកដល់ជនគ្រប់រូប និងមិនកំណត់ថាប្រជាជនដោយឡែកមួយណាឡើយ។

គ) អាជ្ញាធរវិទ្យាសាស្ត្រជាច្រើនបានកំណត់ថា ការស្រូបផ្សែងបារីដោយអចេតនាបង្កឱ្យកើតមហារីក។ ភាគីជាច្រើននៃអនុសញ្ញារបស់អង្គការសុខភាពពិភពលោក (ឧទាហរណ៍ ប្រទេសហ្វាំងឡង់ និងអាល្លឺម៉ង់)បានធ្វើចំណាត់ថ្នាក់ថា ការស្រូបផ្សែងបារីដោយអចេតនាបង្កឱ្យកើតមហារីក និងរួមទាំងការពារចំពោះការប្រឈមនេះនៅកន្លែងធ្វើការរបស់ពួកគេ និងច្បាប់សុវត្ថិភាព។ លើសពីនេះទៀត ដើម្បីឆ្លើយតបនឹងមាត្រាទី៨ ភាគីទាំងអស់អាចមានកាតព្វកិច្ច ដោះស្រាយគ្រោះថ្នាក់នៃការប្រឈមនឹងផ្សែងបារី ដោយអនុលោមទៅតាមច្បាប់ស្ដីពីទីកន្លែងធ្វើការជាធរមាន និងច្បាប់គ្រប់គ្រងការប្រឈមនឹងគ្រោះថ្នាក់នៃសារធាតុពុលផ្សេងទៀត រួមទាំងបញ្ហាមហារីកផងដែរ។

**គោលការណ៍ និងនិយមន័យពាក់ព័ន្ធផ្សេងៗ ក្នុងក្របខ័ណ្ឌការពារពីការប្រឈមនឹងផ្សែងបារី**

**គោលការណ៍**

៥. ដូចកំណត់បង្ហាញក្នុងមាត្រាទី៤ នៃអនុសញ្ញារបស់អង្គការសុខភាពពិភពលោក ឆន្ទៈនយោបាយដ៏មុះមុតគឺជាភាពចាំបាច់ ដើម្បីចាត់វិធានការ ការពារជនគ្រប់រូបពីការប្រឈមនឹងផ្សែងបារី។ កិច្ចព្រមព្រៀងផ្អែកលើគោលការណ៍ដូចខាងក្រោមនេះ ចាត់ទុកថាជាវិធានការ ដែលអាចចង្អុលបង្ហាញការអនុវត្តន៍មាត្រាទី៨ នៃអនុសញ្ញា។

**គោលការណ៍ទី១**

៦. វិធានការមានប្រសិទ្ធិភាព ដែលផ្តល់ការការពារចំពោះការប្រឈមនឹងផ្សែងបារី ដូចជាការចង់បាននៃមាត្រា ទី៨ នៃអនុសញ្ញារបស់អង្គការសុខភាពពិភពលោក តំរូវឱ្យលប់បំបាត់ទាំងស្រុងការជក់បារី និងផ្សែងបារី ក្នុងកន្លែង ឬបរិស្ថានពិសេស ដើម្បីបង្កើតច្បាប់បរិស្ថានគ្មានផ្សែងបារី១០០%។ ពុំមានកំរិតមានសុវត្ថិភាពនៃការស្រូបផ្សែងបារី និងកំណត់បង្ហាញផ្សេង១ ដូចជាកំរិតខ្ពស់ទាបរបស់ផ្សែងបារី គួរត្រូវបានបដិសេធន៍ ហើយវាត្រូវបានបដិសេធន៍ដោយភស្តុតាងវិទ្យាសាស្ត្រ។ ដំណោះស្រាយផ្សេងក្រៅពីច្បាប់បរិស្ថានគ្មានផ្សែងបារី១០០% រួមមានប្រព័ន្ធបឺតខ្យល់ ចំរោះខ្យល់ និងការបង្កើតកន្លែងជក់បារីដោយឡែក (ទោះបីមាន ឬគ្មានប្រព័ន្ធបឺតខ្យល់) មានការបង្ហាញដដែល១ថាគ្មានប្រសិទ្ធិភាព ហើយក៏មានភស្តុតាងសន្និដ្ឋានតាមបែបវិទ្យាសាស្ត្រ ឬតាមវិធីផ្សេងទៀត បញ្ជាក់ច្បាស់ថាដំណោះស្រាយបែបវិស្វកម្មនេះពុំអាចការពារការប្រឈមនឹងផែសងបារីបានទេ។

**គោលការណ៍ទី២**

៧. ជនគ្រប់រូបគួរត្រូវបានការពារចំពោះការប្រឈមនឹងផ្សែងបារី។ គ្រប់កន្លែងធ្វើការ និងទីសាធារណៈបិទជិតគួរតែជាកន្លែងគ្មានផ្សែងបារី។

**គោលការណ៍ទី៣**

៨. ច្បាប់ចាំបាច់សំរាប់ការពារជនគ្រប់រូបចំពោះការប្រឈមនឹងផ្សែងបារី។ គោលនយោបាយគ្មានផ្សែងបារីដោយស្ម័គ្រចិត្តបង្ហាញថាគ្មានប្រសិទ្ធិភាព និងមិនអាចផ្តល់ការការពារបានគ្រប់គ្រាន់ឡើយ។ ដើម្បីឱ្យមានប្រសិទ្ធិភាព ច្បាប់ត្រូវតែសាមញ្ញ ច្បាស់ និងអាចអនុវត្តបាន។

**គោលការណ៍ទី៤**

៩. ផែនការត្រឹមត្រូវ ហើយមានធនធានគ្រប់គ្រាន់ គឺជាការចាំបាច់ ដើម្បីការអនុវត្តន៍បានជោគជ័យ និងពង្រឹងច្បាប់គ្មានផ្សែងបារី។

**គោលការណ៍ទី៥**

១០.សង្គមស៊ីវិលមានតួនាទីសំខាន់ក្នុងការគាំទ្រច្បាប់ និងធានាបំពេញបន្ថែមវិធានការគ្មានផ្សែងបារី ហើយគួរតែរួមបញ្ចូលដៃគូសកម្ម ក្នុងដំណើរការបង្កើត អនុវត្ត និងពង្រឹងការអនុវត្តន៍ច្បាប់។

**គោលការណ៍ទី៦**

១១. ការអនុវត្តន៍ច្បាប់គ្មានផ្សែងបារី ពង្រឹងការអនុវត្តន៍ និងផលវិបាករបស់វាគួរត្រូវបានតាមដាន និងវាយតំលៃ។ វាគួរត្រូវបានរួមបញ្ចូលការតាមដាន និងឆ្លើយតបទៅនឹងសកម្មភាពរបស់ឧស្សាហកម្មថ្នាំជក់ ដែលពន្យឺត

ការអនុវត្តន៍ និងការពង្រឹងការអនុវត្តន៍ច្បាប់ ដូចបានកំណត់ក្នុងមាត្រា២០.៤ នៃអនុសញ្ញារបស់អង្គការសុខភាពពិភពលោក។

**គោលការណ៍ទី៧**

១២. ការការពារប្រជាជនពីការប្រឈមនឹងផ្សែងបារីគួរត្រូវបានពង្រឹង និងពង្រីក។ បើចាំបាច់គួររួមបញ្ចូលសកម្មភាពថ្មីៗ ឬធ្វើវិសោធនកម្មច្បាប់ បង្កើនការអនុវត្តន៍ និងវិធានការផ្សេងៗទៀត ដើម្បីឆ្លុះបញ្ចាំងនឹងភ័ស្តុតាងវិទ្យាសាស្ត្រថ្មី និងបទពិសោធន៍នៃករណីសិក្សាផ្សេងៗ។

**និយមន័យ**

១៣.វាមានសារសំខាន់ណាស់ ចំពោះការប្រើ និងកំណត់ន័យនៃវាក្យស័ព្ទគន្លឹះ ក្នុងការបង្កើតច្បាប់។ អនុសាសន៍ជាច្រើន ដូចជាដើម្បីកំណត់និយមន័យសមស្រប ផ្អែកលើបទពិសោធន៍នៃប្រទេសជាច្រើនត្រូវបានបង្កើតនៅពេលនេះ។ និយមន័យនៅក្នុងផ្នែកនេះ បំពេញបន្ថែមនិយមន័យ ដែលមាននៅក្នុងអនុសញ្ញារបស់អង្គការសុខភាពពិភពលោក។

- **ការស្រូបផ្សែងបារីដោយអចេតនា ឬ បរិស្ថានមានផ្សែងបារី**

១៤. ពាក្យគន្លឹះជាច្រើនត្រូវបានប្រើញឹកញាប់ ដើម្បីពិពណ៌នាពីប្រភេទនៃផ្សែងបារី ដែលបានលើកឡើងនៅក្នុងមាត្រាទី៨ នៃអនុសញ្ញារបស់អង្គការសុខភាពពិភពលោក។ ពាក្យទាំងនោះរួមមាន :" **ការស្រូបផ្សែងបារីដោយអចេតនា** " " **បរិស្ថានមានផ្សែងបារី** " " **ផ្សែងបារីអ្នកដទៃ** " " **ស្រូបផ្សែងបារីដោយប្រយោល** " **និង** " **ការប្រឈមនឹងផ្សែងបារី ដោយអចេតនា** " គួរត្រូវជៀសវាង ដូចជាបទពិសោធន៍នៅប្រទេសបារាំង និងកន្លែងផ្សេងទៀត សំណូមពរដល់ក្រុមហ៊ុនថ្នាំជក់ឱ្យប្រើវាក្យស័ព្ទទាំងនេះ ដូចជាជំនួសពាក្យ "**ដោយស្ម័គ្រចិត្ត**" ដោយពាក្យ" **ប្រឈម**" ហើយពាក្យ " **ការស្រូបផ្សែងបារីដោយអចេតនា**"និង" **បរិស្ថានមានផ្សែងបារី**"។ នៅក្នុងគោលការណ៍ណែនាំនេះ ប្រើពាក្យ" **ការស្រូបផ្សែងបារីដោយអចេតនា**"។

១៥. **ការស្រូបផ្សែងបារីដោយអចេតនា** អាចមានន័យថា ជាផ្សែងបារីដែលហុយចេញពីចុងបារីដុតឆេះ ឬផលិតផលថ្នាំជក់ផេសងទៀត រួមនឹងផ្សែងដែលបានផ្លុំចេញដោយអ្នកជក់។

១៦. **ខ្យល់គ្មានផ្សែងបារី** គឺជាខ្យល់ដែលគ្មានផ្សែងបារី១០០%។ និយមន័យនេះរួមបញ្ចូលខ្យល់ដែលមានផ្សែងបារីដែលមិនអាចមើលឃើញ ហិត ទទួលអារម្មណ៍ដឹង ឬអាចវាស់បាន។

- **ការជក់បារី**

១៧. ពាក្យនេះមានន័យរួមបញ្ចូល ការកានបារីជក់ ឬតាមមើលពន្លឺផលិតផលថ្នាំជក់ដោយមិនដឹងខ្លួនក៏ដោយ ក៏ផ្សែងនោះត្រូវបានហឺតចូល ឬបញ្ចេញចោលយ៉ាងសកម្មដែរ។

- **កន្លែងសាធារណៈ**

១៨. ក្នុងខណៈពេលកំណត់និយមន័យឱ្យបានច្បាស់លាស់ អំពី **កន្លែងសាធារណៈ** វានឹងខុសគ្នាពីយុត្តាធិការមួយទៅយុត្តាធិការមួយទៀត ដូច្នេះវាមានសារៈសំខាន់ណាស់ ដែលច្បាប់ត្រូវកំណត់ន័យនៃពាក្យនេះឱ្យបានទូលាយតាមអាចធ្វើបាន។ និយមន័យបានប្រើគួរតែគ្របដណ្តប់គ្រប់កន្លែងទាំងអស់ដែលប្រជាជនទូទៅប្រើប្រាស់ ឬកន្លែងប្រមូលផ្តុំ ទោះបីជាម្ចាស់កម្មសិទ្ធិ ឬមានសិទ្ធិប្រើប្រាស់ក៏ដោយ។

- **ទីកន្លែងបិទជិត**

១៩. មាត្រាទី៨ តំរូវឱ្យមានការការពារពីផ្សែងបារី ក្នុងកន្លែងធ្វើការបិទជិត និងកន្លែងសាធារណៈ។ ដោយសារសក្តានុពលប្រកបដោយគ្រោះថ្នាក់ ក្នុងការកំណត់ន័យ " តំបន់បិទជិត " បទពិសោធន៍នៃប្រទេសជាច្រើន ការកំណត់ន័យនៃពាក្យនេះ គួរត្រូវបានបញ្ជាក់ឱ្យច្បាស់លាស់។ និយមន័យ គួរត្រូវបានរួមបញ្ចូល និងច្បាស់លាស់ ហើយការថែទាំ គួរត្រូវបានកំណត់ន័យ ដើម្បីជៀសវាងការបង្កើតបញ្ជី ដែលអាចត្រូវបានបកស្រាយ ថាជាការដកចេញ សក្តានុពលជាប់ពាក់ព័ន្ធនឹង "តំបន់បិទជិត " ។ វាត្រូវបានគេផ្តល់អនុសាសន៍ថា "តំបន់បិទជិត" មានន័យថា ការរួមបញ្ចូលកន្លែងចំហទាំងលាយណា ដែលគ្របដោយដំបូល បិទដោយជញ្ជាំងមួយ ឬច្រើន ទោះបីជាសម្ភារៈសំរាប់ធ្វើដំបូល ឬជញ្ជាំង ជាប្រភេទអ្វីក៏ដោយ ហើយទោះបីជារចនាសម្ព័ន្ធជាលក្ខណៈអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នក៏ដោយ។

- **កន្លែងធ្វើការ**

២០. កន្លែងធ្វើការ គួរត្រូវបានកំណត់ន័យឱ្យទូលាយថា " កន្លែងទាំងឡាយណា ដែលបានប្រើប្រាស់មនុស្សក្នុងពេលពួកគេធ្វើការ ឬបំពេញការងារ " ។ វាគួររួមបញ្ចូលមិនត្រឹមតែសំរាប់សំណងការងារ ប៉ុន្តែសំរាប់ការងារស្ម័គ្រចិត្តផងដែរ ប្រសិនបើប្រភេទនៃសំណងនោះជាការទូទាត់ធម្មតា។ លើសពីនេះទៀត កន្លែងធ្វើការមិនត្រឹមតែរួមបញ្ចូលកន្លែងអនុវត្តកាងារទាំងឡាយណាប៉ុណ្ណោះទេ តែវារួមបញ្ចូលកន្លែងផ្សេងៗ ដែលពាក់ព័ន្ធការបំរើការងារ ឧទាហរណ៍ ដូចជាច្រកចូល ជណ្តើរយន្ត ជណ្តើរ បន្ទប់ទទួលភ្ញៀវ គន្លែងទំនាក់ទំនងផ្សេងៗ កង់ទីន បន្ទប់ទឹក កន្លែងរង់ចាំ បន្ទប់បាយថ្ងៃត្រង់ និងរួមបញ្ចូលផ្ទៃលខាងក្រៅអគារផងដែរ ដូចជា

ឃ្លាំង និងកន្លែងជ្រក។ រថយន្តប្រើប្រាស់ក្នុងកន្លែងធ្វើការ ក៏ជាកន្លែងធ្វើការដែរ ដូច្នេះគួរកំណត់ដោយឡែកផងដែរ។

២១. ពិចារណាដោយប្រុងប្រយ័ត្នចំពោះ កន្លែងសំរាប់បុគ្គលម្នាក់ ឬកន្លែងស្នាក់នៅ គួរត្រូវកំណត់ថាជាកន្លែងធ្វើការ ឧទាហរណ៍ មន្ទីរឃុំឃាំង កន្លែងព្យាបាលសុខភាពផ្លូវចិត្ត សាលគិលានុប្បដ្ឋាក។ កន្លែងទាំងនេះក៏ជាកន្លែងធ្វើការ ដូច្នេះតើអ្នកណាខ្លះគួរត្រូវបានការពារចំពោះការប្រឈមនឹងផ្សែងបារី។

- **មធ្យោបាយដឹកជញ្ជូនសាធារណៈ**

២២. មធ្យោបាយដឹកជញ្ជូនសាធារណៈ មានន័យថា រាល់រថយន្តទាំងអស់ ដែលបានដឹកសាធារណៈជនទូទៅក្នុងគោលបំណងពាណិជ្ជកម្ម ហើយរួមបញ្ចូលតាក់ស៊ីផងដែរ។

## ទំហំនៃប្រសិទ្ធិភាពច្បាប់

២៣. មាត្រាទី៨ តំរូវឱ្យមានការសំរបសំរួលរកវិធានការមានរបសិទ្ធិភាព ដើម្បីការពារមនុស្សពីការរងផ្សែងបារីនៅក្នុង ១) កន្លែងធ្វើការបិទជិត ២) កន្លែងសាធារណៈបិទជិត ៣) មធ្យោបាយដឹកជញ្ជូនសាធារណៈ និង ៤) កន្លែងសាធារណៈសមស្របផ្សេងទៀត

២៤. នេះជាការបង្កើតកាតព្វកិច្ចដើម្បីការពារទូទៅ ដោយធានាថា កន្លែងសាធារណៈបិទជិត កន្លែងធ្វើការបិទជិតទាំងអស់ និងកន្លែងសាធារណៈសមស្របផ្សេងទៀត (កន្លែងបើកចំហ ឬស្ទើរតែបើកចំហ) ត្រូវតែគ្មានការប្រឈមនឹងការស្រូបផ្សែងបារីដោយអចេតនា។ គ្មានការលើកលែងណាមួយ ត្រូវបានសំរបសំរួលដោយផ្អែកលើមូលដ្ឋានសុខភាព ឬភស្តុតាងច្បាប់នោះទេ។ បើសិនមានការលើកលែងត្រូវបានពិចារណាដោយផ្អែកលើហេតុផលផ្សេង២ ទាំងនេះគួរត្រូវបានធ្វើឱ្យតិចបំផុត។ លើសពីនេះទៀត បើសិនភាគីណាមួយមិនមានលទ្ធភាពសំរេចជាសកលភ្លាម២ទេ កាតព្វកិច្ចបន្តនៅក្នុងមាត្រាទី៨ ដើម្បីដកចេញភ្លាមនូវការលើកលែងទាំងនោះ ហើយបង្កើតការការពារជាសកល។ ភាគីនិមួយ២គួរតែខិតខំ ផ្តល់នូវការការពារជាសកល ក្នុងរយៈពេល៥ឆ្នាំ នៃការចូលជាធរមាននៃអនុសញ្ញារបស់អង្គការសុខភាពពិភពលោក របស់ភាគីនោះ។

២៥. គ្មានកំរិតមានសុវត្ថិភាពចំពោះការប្រឈមនឹងការស្រូបផ្សែងបារីដោយអចេតនា ហើយក៏ដូចជាការទទួលស្គាល់សេចក្តីសំរេចចិត្ត FCTC/COP1(15) ដោយសន្និសិទភាគី ដំណោះស្រាយបែបវិស្វកម្ម ដូចជាមាស៊ីនបឺតខ្យល់ ការផ្លាស់ប្តូរខ្យល់ និងការបង្កើតតំបន់ជក់បារីដោយឡែក មិនអាចការពារការប្រឈមនឹងផ្សែងបារីបានទេ។

២៦. ការការពារគួរត្រូវបានផ្តល់ឱ្យគ្រប់កន្លែងធ្វើការទាំងអស់ រួមទាំងយានយន្តប្រើជាសាធារណៈនៅកន្លែងធ្វើការ (ឧ. តាក់ស៊ី រថយន្តសង្គ្រោះ រថយន្តរត់សំបុត្រ)។

២៧. អត្ថន័យនៃសន្និសញ្ញា ត្រូវមានវិធានការការពារ មិនគ្រាន់តែនៅកន្លែងសាធារណៈបិទជិតទាំងអស់ទេ តែកន្លែងសាធារណៈសមស្របផ្សេងទៀត(កន្លែងបើកចំហឬស្ទើរតែបើកចំហ)។ ការកំណត់កន្លែងសាធារណៈបើកចំហ ឬស្ទើរតែបើកចំហ ដែលត្រូវបានកំណត់ដោយច្បាប់ ភាគីនីមួយៗគួរតែពិចារណាលើហេតុផលសមស្រប ដូចជាអាចបង្កគ្រោះថ្នាក់ដល់សុខភាព នៅកន្លែងផ្សេងៗ និងគួរតែសំរបសំរួលឱ្យមានការការពារមានប្រសិទ្ធិភាពបំផុតចំពោះការប្រឈម នៅកន្លែងណាដែលមានភ័ស្តុតាងបង្ហាញថា មានកាបង្កគ្រោះថ្នាក់។

**ការជូនដំណឹង ការពិគ្រោះយោបល់ និងការចូលរួមជាមួយសាធារណៈ ដើម្បីធានាការគាំទ្រ និងការអនុវត្តន៍ ដោយរលូន**

២៨. ការបង្កើនចំណេះដឹងក្នុងចំណោមសាធាណៈជន និងអ្នកដឹកនាំ អំពីគ្រោះថ្នាក់នៃការប្រឈមចំពោះការស្រូបផ្សែងបារីដោយអចេតនា តាមរយៈយុទ្ធនាការជាប្រចាំ មានតួនាទីសំខាន់ ចំពោះភ្នាក់ងាររដ្ឋាភិបាលភាពជាដៃគូជាមួយសង្គមស៊ីវិល ដើម្បីធានាថា សាធារណៈជនយល់ និងគាំទ្រសកម្មភាពអនុវត្តច្បាប់។ អ្នកចូលរួមពាក់ព័ន្ធសំខាន់ៗរួមមាន ផ្នែកវិនិយោគ ភោជនីយដ្ឋាន សមាគមន៍សណ្ឋាគារ ក្រុមនិយោជក់សហជីពពាណិជ្ជកម្ម ប្រព័ន្ធផ្សព្វផ្សាយ អ្នកប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អង្គការតំណាងកុមារ និងយុវជនវិទ្យស្ថានសិក្សា និងជំនឿ សហគមន៍ស្រាវជ្រាវ និងសាធារណៈជនទូទៅ។ ការប្រឹងប្រែងបង្កើនចំណេះដឹងគួររួមបញ្ចូលការពិគ្រោះយោបល់លើភាពប៉ះពាល់ពាណិជ្ជកម្ម អង្គការ និងវិទ្យាស្ថានផ្សេងៗក្នុងដំណើរការបង្កើតច្បាប់។

២៩. សារគន្លឹះគួរផ្តោតលើ គ្រោះថ្នាក់បណ្តាលមកពីការប្រឈមនឹងការស្រូបផ្សែងបារីដោយអចេតនា។ ជាការពិត ការលប់បំបាត់ផ្សែងបារីនៅកន្លែងបិទជិតគឺជាដំណោះស្រាយផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រតែមួយគត់ដើម្បីធានានូវការការពារដ៏ពេញលេញ ចំពោះការប្រឈមនឹងផ្សែងបារី សិទ្ធិទទួលបានការការពារដោយច្បាប់ដូចៗគ្នា និងពុំមានការខាតបង់ពាណិជ្ជកម្ម រវាងសុខភាព និងសេដ្ឋកិច្ច ព្រោះមានបទពិសោធន៍ជាច្រើនបង្ហាញថា ការបង្កើនប្រព័ន្ធយុត្តាធិការ ចំពោះបរិស្ថានគ្មានផ្សែងបារី ទទួលបានផលប្រយោជន៍ទាំងសេដ្ឋកិច្ច និងសុខភាព។ យុទ្ធនាការអប់រំសាធារណៈ គួរកំណត់ទីតាំងដែលច្បាប់មិនអាចអនុវត្តបាន ដូចជាផ្ទះឯកជន។

៣០. ការពិគ្រោះយោបល់ទូលំទូលាយជាមួយអ្នកពាក់ព័ន្ធ មានសារៈសំខាន់ចំពោះការអប់រំ និងចលនាសហគមន៍ និងសំរបសំរួលគាំទ្រការអនុវត្តន៍ច្បាប់បន្ទាប់ពីការអនុម័ត។ ពេលច្បាប់ត្រូវបានអនុម័ត គួរតែមានយុទ្ធនាការអប់រំ ដែលនាំទៅរកការអនុវត្តន៍។ បញ្ញត្តិព័ត៏មានផ្សេងៗ សំរាប់ម្ចាស់ជំនួញ និងអ្នកគ្រប់គ្រងអគារ

តំរង់ទិសរកច្បាប់ ការទទួលខុសត្រូវរបស់ពួកគេ និងការការពារធនធាន។ វិធានការទាំងនេះនឹងបង្កើនភវនីយភាពនៃការអនុវត្តន៍ដោយរលូន និងកំរិតខ្ពស់នៃការអនុវត្តន៍តាមដោយស្ម័គ្រចិត្ត។ សារដើម្បីផ្តល់អំណាចដល់អ្នកមិនជក់បារី និងអរគុណអ្នកជក់បារី ដែលគោរពច្បាប់ នេះនឹងលើកកំពស់ការចូលរួមរបស់សាធារណៈ ក្នុងការពង្រឹង និងអនុវត្តន៍ច្បាប់ដោយរលូន។

## ប្រតិបត្តិការ

### ភារកិច្ចអនុវត្តតាម

៣១. ច្បាប់មានរបសិទ្ធិភាពគួរ គួរជំរុញឱ្យមានការទទួលខុសត្រូវជាផ្លូវច្បាប់ សំរាប់ការបង្ក្រប់ទាំងផលប៉ះពាល់លើការបង្កើតជំនួញ បុគ្គលអ្នកជក់បារី និងគួរត្រូវពិន័យដល់ការរំលោភ ដែលត្រូវអនុវត្តចំពោះជំនួញភាពដែលអាចកើតមាន និងអ្នកជក់បារី។ ការប្រតិបត្តិគួរផ្តោតជាពិសេសលើការបង្កើតជំនួញ។ ច្បាប់ត្រូវដាក់ការទទួលខុសត្រូវចំពោះការគោរពតាមរបស់ម្ចាស់ អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវផ្សេងទៀតនៃទីតាំងនោះ និងត្រូវកំណត់ឱ្យច្បាស់សកម្មភាព ដែលពួកគេត្រូវការ។ ភារកិច្ចទាំងនេះរួមមាន :

ក) ការបិតតាំងសញ្ញាឱ្យបានច្បាស់នៅច្រកចូល និតទីតាំងសមស្របផ្សេងទៀត រួមទាំងសញ្ញាមិនអនុញ្ញាតិឱ្យជក់បារី។ ទំរង់ និងខ្លឹមសារនៃសញ្ញាទាំងនេះ គួរត្រូវបានកំណត់ដោយអាជ្ញាធរសុខាភិបាល ឬភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀត និងគួរមានបញ្ជាក់លេខទូរស័ព្ទ និងនិតិវិធីផ្សេងទៀត សំរាប់សាធារណៈជនរាយការណ៍ពីការរំលោភបំពាន និងឈ្មោះនៃបុគ្គលនៅស្ថាប័ននោះ ដើម្បីឱ្យពួកគេអាចផ្តល់យោបល់បាន។

ខ) ភារកិច្ចប្រមូលចោលប្រដាប់គោះបារីទាំងអស់ពីអគារ ឬកន្លែងធ្វើការ។

គ) ភារកិច្ចអភិបាលការគោរពតាមបទបញ្ជារ

ឃ) ភារកិច្ចរៀបចំជំហានសមស្របជាក់លាក់មួយ ដើម្បីរារាំងបុគ្គលម្នាក់ៗពីផ្សេងបារីនៅក្នុងបរិវេណ។ ជំហានទាំងនេះអាចរួមមាន ស្នើសុំជនគ្រប់រូបកុំជក់បារី ផ្អាកសេវាកម្ម ចាកចេញពីបរិវេណ និងទំនាក់ទំនងជាមួយនឹងភ្នាក់ងារប្រតិបត្តិ ឬអាជ្ញាធរផ្សេងទៀត។

### កាដាក់ពិន័យ

៣២. ច្បាប់គួរកណត់ទោសឱ្យច្បាស់លាស់ ឬការពិន័យជាប្រាក់ផ្សេងទៀតចំពោះការរំលោភ។ ខណៈពេលទំហំនៃការពិន័យនេះ ចាំបាច់ឆ្លុះបញ្ចាំងនឹងការអនុវត្តន៍ជាក់ស្តែង ហើយស្ថាប័នគយនៃប្រទេសនិមួយៗ គោលការណ៍មួយចំនួន គួរណែនាំដល់ការសំរេចចិត្ត។ សំខាន់ជាងនេះទៀត ការពិន័យគួរមានកំរិតទោសធ្ងន់ធ្ងរគ្រប់គ្រាន់ ដើម្បីឱ្យរាងចាលចំពោះការរំលោភបំពាន ឬពួកគេអាចត្រូវបានព្រងើយកណ្តើយ ដោយអ្នករំលោភ

ឬត្រូវបានប្រព្រឹត្តិដូចជា ការចំណាយចំពោះពាណិជ្ជកម្មប៉ុណ្ណោះ។ ការពិន័យត្រូវអនុវត្តកាន់តែធ្ងន់ធ្ងរ និងរាំងចាលចំពោះអ្នករំលោភដែលជាអ្នកជំនួញ បុគ្គលជក់បារី ដែលជាធម្មតាមានធនធានតិចតួច។ ការពិន័យត្រូវបង្កើនឡើងចំពោះការរំលោភបំពានដដែលៗ ហើយស្របនឹងប្រព្រឹត្តិកម្មប្រទេសផ្សេង និងដូចគ្នាផងដែរចំពោះការរំលោភធ្ងន់ធ្ងរ។

៣៣. លើសពីនេះទៀតការពិន័យជាប្រាក់ ច្បាប់អាចអនុញ្ញាតិផងដែរសំរាប់ការផ្តល់រង្វាន់ ឬដាក់ទណ្ឌកម្មផ្នែករដ្ឋបាល ដូចជាការពន្យារលិខិតអនុញ្ញាតិពាណិជ្ជកម្ម ស្របនឹងការអនុវត្តន៍ និងប្រព័ន្ធច្បាប់របស់ប្រទេសនិមួយៗ។ ការផ្តល់រង្វាន់ ឬដាក់ទណ្ឌកម្មចំពោះរម្យណីយដ្ឋានទាំងនេះ កំរត្រូវបានប្រើប្រាស់ ប៉ុន្តែវាមានសារៈសំខាន់សំរាប់ការពង្រឹងច្បាប់ ប្រឆាំងរាល់ជំនួញដែលជ្រើសរើសការបង្កហេតុដដែលៗ។

៣៤. ការពិន័យឧក្រិដ្ឋជន ដែលរំលោភច្បាប់ អាចត្រូវបានពិចារណារួមបញ្ចូល ប្រសិនបើសមស្របចំពោះច្បាប់ និងបរិបទវប្បធម៌ប្រទេសនិមួយៗ។

**ពង្រឹងហេដ្ឋារចនាសម្ព័ន្ធ**

៣៥. ច្បាប់គួរកំណត់អាជ្ញាធរមានសមត្ថកិច្ច សម្រាប់ពង្រឹង និងបញ្ចូលប្រព័ន្ធតាមដានការប្រតិបត្តិ និងសំរាប់ការកាត់ទោសអ្នករំលោភបំពាន។

៣៦. ការតាមដានរួមបញ្ចូលដំណើការត្រួតពិនិត្យប្រតិបត្តិការពាណិជ្ជកម្ម។ វាពុំសូវមានការចាំបាច់ ដើម្បីបង្កើតប្រព័ន្ធត្រួតពិនិត្យថ្មី សំរាប់ពង្រឹងការអនុវត្តន៍ច្បាប់គ្មានផ្សែងបារី។ ការប្រតិបត្តិអាចត្រូវបានតាមដានជាពិសេស ជាជាងការប្រើប្រាស់និតិវិធីដែលមានស្រាប់មួយ ឬច្រើន សំរាប់ត្រួតពិនិត្យបរិវេណពាណិជ្ជកម្ម និងកន្លែងធ្វើការ។ ជាធម្មតាជំរើសផ្សេងៗមានសំរាប់គោលបំណងណេះ។ ក្នុងប្រទេសជាច្រើន ប្រតិបត្តិការត្រួតពិនិត្យ អាចដាក់បញ្ចូលក្នុងការត្រួតពិនិត្យលិខិតអនុញ្ញាតិពាណិជ្ជកម្ម ការត្រួតពិនិត្យសុខភាព និងអនាម័យ ការត្រួតពិនិត្យសុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការ ការត្រួតពិនិត្យសុវត្ថិភាពអគ្គីភ័យ ឬកម្មវិធីស្រដៀងគ្នា។ វាមានតំលៃក្នុងការប្រើប្រាស់ច្រើនយ៉ាង ដូចចាប្រភពព័ត៌មានប្រមូលបានក្នុងពេលកើតឡើងជាមួយគ្នា។

៣៧. ការប្រើប្រាស់អ្នកត្រួតពិនិត្យ ឬភ្នាក់ងារពង្រឹងការអនុវត្តន៍នៅថ្នាក់មូលដ្ឋានដែលអាចមាន ត្រូវបានផ្តល់អនុសាសន៍ថា វាគួរត្រូវបានបង្កើនការពង្រឹងធនធានដែលមាន និងកំរិតនៃការប្រតិបត្តិ។ ដំណោះស្រាយនេះត្រូវបង្កើតនិតិវិធីសំរបសំរួលថ្នាក់ជាតិមួយ ដើម្បីធានាឱ្យមានដំណោះស្រាយស្របគ្នាទូទាំងប្រទេស។

៣៨. ពាក់ព័ន្ធនឹងនិតិវិធីប្រើប្រាស់ និងការតាមដាន ត្រូវផ្អែកលើផែនការប្រតិបត្តិទាំងមូល និងត្រូវបញ្ចូលដំណើរការបណ្តុះបណ្តាលអ្នកត្រួតពិនិត្យប្រកបដោយប្រសិទ្ធិភាព។ ការតាមដានមានប្រសិទ្ធិភាព អាចរួមផ្សំ

ដោយការត្រួតពិនិត្យទៀងទាត់ ដោយគ្មានកាលបរិច្ឆេទទុកមុន ការត្រួតពិនិត្យមិនឱ្យដឹងខ្លួន ក៏ដូចជាទស្សនៈកិច្ចធ្វើឡើងទៅតាមការរិះគន់។ ការពិនិត្យទាំងនេះ អាចត្រូវបានអប់រំប្រសើរ ក្នុងដំណាក់កាលដំបូងបន្ទាប់ពីច្បាប់ចូលជាធរមាន ដូចជាបទល្មើសភាគច្រើន ហាក់ដូចជាមិនត្រូវបានយកចិត្តទុកដាក់។ ច្បាប់គួរផ្តល់អំណាចដល់អ្នកត្រួតពិនិត្យអាចចូលក្នុងបរិវេណដែលស្ថិតក្រោមច្បាប់ និងអាចប្រមូលគំរូសំណាក និងភ័ស្តុតាង ប្រសិនបើអំណាចទាំងនេះមិនទាន់ត្រូវបានដាក់បញ្ចូលក្នុងច្បាប់ដែលមានស្រាប់។ ស្រដៀងគ្នានេះដែរ ច្បាប់គួរហាមឃាត់ជំនួញដែលបង្កឧបសគ្គដល់អ្នកត្រួតពិនិត្យក្នុងការងាររបស់ពួកគេ។

៣៩. ការចំណាយសំរាប់ការតាមដានឱ្យមានប្រសិទ្ធិភាពមិនត្រូវច្រើនលើសលប់ពេកទេ។ វាមិនចាំបាច់ជួលអ្នកត្រួតពិនិត្យច្រើនពេកទេ ព្រោះអ្នកត្រួតពិនិត្យ អាចសំរេចបានតាមរយៈកម្មវិធី និងបុគ្គលិកដែលមានស្រាប់ ហើយបទពិសេធន៍បង្ហាញថា គោលនយោបាយគ្មានផ្សែងបារីដែលអនុវត្តកាន់តែឆាប់ កាន់តែឆាប់ត្រូវបានពង្រឹង (វាត្រូវបានពង្រឹងការអនុវត្តន៍ដ៏ខ្លាំងក្លា ដោយសាធារណៈជន)។ មានការពិន័យតិចតួចអាចនឹងត្រូវបានអនុវត្ត បើសិនច្បាប់ត្រូវបានអនុវត្តយ៉ាងម៉ឺងម៉ាត់ និងការប្រឹងប្រែងដ៏សកម្ម ដើម្បីអប់រំអ្នកជំនួញ និងសាធារណៈជន។

៤០. ទោះបីជាយ៉ាងណាក៏ដោយកម្មវិធីទាំងនេះពុំសូវចំណាយអស់ច្រើនប៉ុន្មានទេ ប្រភពជាច្រើនត្រូវបានបណ្តុះបណ្តាល ដូចជាអ្នកជំនួញ អ្នកត្រួតពិនិត្យ សំរបសំរួលដំណើរការត្រួតពិនិត្យ និងបំពេញការខ្វះខាតដល់បុគ្គលិក ដែលចុះត្រួតពិនិត្យកន្លែងជំនួញ នៅក្រៅម៉ោងធ្វើការធម្មតា។ និតិវិធីប្រើប្រាស់ថវិកាគួរត្រូវបានកំណត់ឱ្យច្បាស់លាស់ចំពោះគោលបំណងនេះ។ កម្មវិធីត្រួតពិនិត្យមានប្រសិទ្ធិភាពបានប្រើប្រាស់ប្រភពថវិកាផ្សេងៗ រួមទាំងចំណូលពន្ធបន្ថែម តំលៃប័ណ្ណប៉ាតង់ ចំណូលដែលបានពីការផាកពិន័យពីអ្នកបំពាន។

**យុទ្ធសាស្ត្រពង្រឹងការអនុវត្តន៍**

៤១. ដំណោះស្រាយជាយុទ្ធសាស្ត្រដើម្បីពង្រឹងអាចប្រតិបត្តិជាអតិបរមា អនុវត្តច្បាប់ជាធម្មតា និងកាត់បន្ថយកំរិតចំណាយការអនុវត្តន៍ចាំបាច់។

៤២. ជាពិសេស ការពង្រឹងក្នុងដំណាក់កាលភ្លាមៗ ដោយយោលទៅតាមការចូលជាធរមានរបស់ច្បាប់ គឺជាភាពគ្រោះថ្នាក់ ដើម្បីឱ្យច្បាប់បានទទួលជោគជ័យ និងជោគជ័យក្នុងការអនុវត្តន៍ និងការតាមដាននាអនាគត។ យុត្តាធិការជាច្រើនផ្តល់អនុសាសន៍ថា ក្នុងដំណាក់កាលដំបូងនៃការប្រតិបត្តិដោយភាពទន់ភ្លន់ ក្នុងកំឡុងពេលដែលអ្នករំលោភត្រូវបានព្រមាន តែមិនផាកពិន័យ។ ដំណោះស្រាយនេះគួរត្រូវបានរួមបញ្ចូលដោយយុទ្ធនាការដ៏សកម្ម ដើម្បីអប់រំម្ចាស់ជំនួញ អំពីការទទួលខុសត្រូវរបស់ពួកគេចំពោះមុខច្បាប់ ហើយរាល់ជំនួញត្រូវយល់ថា ភាពអនុគ្រោះក្នុងជំនាក់កាលដំបូង ឬដំណាក់កាលចូលជាធរមាន ត្រូវផ្អែកទៅតាមការប្រតិបត្តិដ៏ម៉ឺងម៉ាត់។

៤៣. នៅពេលការប្រតិបត្តិដ៏សកម្មចាប់ផ្តើម យុត្តាធិការជាច្រើនផ្តល់អនុសាសន៍ថា ត្រូវប្រើនីតិវិធីកាត់ទោស ដើម្បីពង្រឹងការគោរពច្បាប់។ ការកំណត់ឱ្យច្បាស់អ្នករំលោភជាក់ស្តែង ដែលបានបំពានលើច្បាប់ ឬអ្នកត្រូវបានគេទទួលស្គាល់នៅក្នុងសហគមន៍ តាមរយៈការធ្វើសកម្មភាពដោយម៉ឺងម៉ាត់ និងឆាប់រហ័ស និងតាមរយៈការស្វែងរកការយល់ដឹងជាអតិបរមារបស់សាធារណៈជន និងអាជ្ញាធរដែនដី មានលទ្ធភាពបង្ហាញដំណោះស្រាយរបស់ពួកគេ និងភាពប្រាកដប្រជានៃច្បាប់។ ការនេះបង្កើនប្រតិបត្តិការដោយស្ម័គ្រចិត្ត និងកាត់បន្ថយប្រភពតំរូវការសំរាប់ការតាមដាន និងការអនុវត្តន៍នាអនាគត។

៤៤. ខណៈដែលច្បាប់គ្មានផ្សែងបារី ក្លាយជារឹងមាំដោយខ្លួនឯងយ៉ាងឆាប់រហ័ស។ ទោះយ៉ាងណាក៏ដោយវាមានសារៈសំខាន់ណាស់ ដែលអាជ្ញាធរដែនដីយកចិត្តទុកដាក់ឆ្លើយតបភ្លាមៗ និងដាច់ខាត ដើម្បីដាក់ឱ្យនៅឯកកោរហូតចំពោះភាពរឹងរូសនៅក្រៅច្បាប់។ ជាពិសេសនៅពេលច្បាប់ចូលជាធរមានដំបូង អាចមានអ្នករំលោភម្តងម្កាល ដែលសំដែងដល់សាធារណៈពីការមិនគោរពច្បាប់។ ការឆ្លើយតបច្បាស់លាស់ក្នុងករណីទាំងនេះកំណត់ការរំពឹងទុកការប្រតិបត្តិខ្ជាប់ខ្ជួន នឹងបង្កើតភាពងាយស្រួលនៃការប្រឹងប្រែងនាអនាគត ខណៈដែលភាពអល់អែកអាចនាំទៅដល់ការរីករាលដាលនៃការបំពានយ៉ាងឆាប់រហ័ស។

**ការចលនា និងការចូលរួមពាក់ព័ន្ធរបស់សហគមន៍**

៤៥. ប្រសិទ្ធិភាពនៃការតាមដាន និងការប្រតិបត្តិកម្មវិធីត្រូវបានពង្រឹងតាមរយៈការចូលរួមរបស់សហគមន៍ក្នុងកម្មវិធី។ ភ្ជាប់ការគាំទ្រសហគមន៍ និងលើកទឹកចិត្តសមាជិកសហគមន៍ ដើម្បីតាមដានការប្រតិបត្តិ និងរបាយកាណ៍រំលោភពង្រីកឱ្យបានទូលំទូលាយដើម្បីឈានដល់ការពង្រឹងស្ថាប័ន និងកាត់បន្ថយប្រភពធនធានដើម្បីសំរេចការប្រតិបត្តិខ្ជាប់ខ្ជួន។ ជាការពិត នៅក្នុងយុត្តាធិការជាច្រើន ការរិះគន់សហគមន៍គឺជាមធ្យោបាយទីមួយនៃការធានាការប្រតិបត្តិខ្ជាប់ខ្ជួន។ ក្នុងគំនិតនេះគោលនយោបាយគ្មានផ្សែងបារី គួរកំណត់ថាសាធារណៈជនអាចចាប់ផ្តើមរិះគន់ និងផ្តល់អំណាចដល់បុគ្គល អង្គការក្រៅរដ្ឋាភិបាលចាប់ផ្តើមសកម្មភាព ដើម្បីបង្ខិតបង្ខំឱ្យមានការប្រតិបត្តិខ្ជាប់ខ្ជួនវិធានការច្បាប់ចំពោះការប្រឈមនឹងការស្រូបផ្សែងបារីដោយអចេតនា។ ការពង្រឹងកម្មវិធីគួររួមបញ្ចូលសេវាទូរស័ព្ទរិះគន់ដោយមិនគិតថ្លៃ ឬប្រព័ន្ធប្រហាក់ប្រហែលគ្នានេះ ដើម្បីលើកទឹកចិត្តសាធារណៈជនឱ្យរាយការណ៍ពីករណីរំលោភបំពាន។

**វិធានការតាមដាន និងវាយតំលៃ**

៤៦. វិធានការតាមដាន និងវាយតំលៃ ដើម្បីកាត់បន្ថយការប្រឈមនឹងផ្សែងបារី មានសារៈសំខាន់ចំពោះហេតុផលជាច្រើន ឧទាហរណ៍ :

ក) បង្កើនការគាំទ្ររបស់អ្នកនយោបាយ និងសាធារណៈជន ដើម្បីពង្រឹងពង្រីកបញ្ញត្តិច្បាប់

ខ) ដើម្បីរៀបចំឯកសារឱ្យមានជោគជ័យ ដែលនឹងជូនដំណឹង និងជួយដល់ការខិតខំរបស់ប្រទេសផ្សេងៗ។

គ) ដើម្បីបញ្ជាក់ និងបោះពុម្ពផ្សាយការខិតខំបានបង្កើតដោយក្រុមហ៊ុនថ្នាំជក់ ក្នុងការអនុវត្តន៍វិធានការរអាច៏កំបាំង។

៤៧. ការពង្រីក និងភាពស្មុគស្មាញនៃការតាមដាន និងវាយតំលៃប្រែប្រួលទៅតាមយុត្តាធិការ ដោយផ្អែកលើភាពជំនាញ និងធនធាន។ ទោះបីយ៉ាងណាក៏ដោយ វាមានសារៈសំខាន់ណាស់ ដើម្បីវាយតំលៃលទ្ធផលនៃវិធានការដែលបានអនុវត្ត ជាពិសេសលើសូចនាករសំខាន់ៗ នៃការប្រឈមនឹងការស្រូបផ្សែងបារីដោយអចេតនានៅកន្លែងធ្វើការ និងកន្លែងសាធារណៈ។ វាអាចជាមធ្យោបាយតំលៃប្រសិទ្ធិភាព ដើម្បីសំរេចបានលទ្ធផលនេះ។ ឧទាហរណ៍ តាមរយៈការប្រើប្រាស់ទិន្នន័យ និងព័ត៏មានដែលបានប្រមូលតាមរយៈសកម្មភាពប្រចាំថ្ងៃ ដូចជាការត្រួតពិនត្យកន្លែងធ្វើការ។

៤៨. មានអភិក្រម និងសូចនាករលទ្ធផលចំនួន៨ ដែលគួរពិចារណា។ គោលនយោបាយរបស់អង្គការសុខភាពពិភពលោក ផ្តល់អនុសាសន៍ អំពីការការពារចំពោះការប្រឈមនឹងការស្រូបផ្សែងបារីដោយអចេតនា ផ្តល់នូវទណ្ឌឡិករណ៍ និងភ្ជាប់ជាមួយការតាមដានស្រាវជ្រាវ ដែលបានរៀបចំនៅកន្លែងផ្សេងលើសូចនាករទាំងអស់នេះ។

**ដំណើរការ**

ក) ចំណេះដឹង ឥរិយាបទ និងការគាំទ្រគោលនយោបាយគ្មានផ្សែងបារី ក្នុងចំណោមប្រជាជនទូទៅ និងក្រុមដែលមានលទ្ធភាពច្បាស់លាស់ ឧទាហរណ៍ អ្នកធ្វើការក្នុងបានីយដ្ឋាន។

ខ) ការពង្រឹង និងការប្រតិបត្តិគោលនយោបាយគ្មានផ្សែងបារី

**លទ្ធផល**

គ) កាត់បន្ថយការប្រឈមនឹងការស្រូបផ្សែងបារីដោយអចេតនារបស់និយោជិក នៅកន្លែងធ្វើការ កន្លែងសាធារណៈ។

ឃ) កាត់បន្ថយចំណុះបរិស្ថានមានផ្សែងបារីក្នុងខ្យល់ នៅកន្លែងធ្វើការ។

ង) កាត់បន្ថយការស្លាប់ និងមានជម្ងឺដោយសារការប្រឈមនឹងការស្រូបផ្សែងបារីដោយអចេតនា។

ច) កាត់បន្ថយការប្រឈមនឹងការស្រូបផ្សែងបារីដោយអចេតនានៅផ្ទះឯកជន។

ឆ) ផ្លាស់ប្តូរប្រេវ៉ាឡង់ការជក់បារី និងឥរិយាបទទាក់ទងនឹងការជក់បារី

ជ) ផលវិបាកសេដ្ឋកិច្ច

## ឧបសម្ព័ន្ធទី២

## ការភ្ជាប់ទំនាក់ទំនងទឹងគំរូច្បាប់ និងប្រភពឯកសារ

1. References to the national and sub-national legislations currently in force that most closely conform to these best practice guidelines are provided below:

(a) United Kingdom of Great Britain and Northern Ireland, Health Act 2006, http://www.opsi.gov.uk/acts/acts2006/20060028.htm

(b) New Zealand, Smoke-free Environments Amendment Act 2003, http://www.legislation.govt.nz/browse_vw.asp?content-set=pal_statutes

(c) Norway, Act No. 14 of 9 March 1973 relating to Prevention of the Harmful Effects of Tobacco, http://odin.dep.no/hod/engelsk/regelverk/p20042245/042041-990030/dok-bn.html (It should be noted however that the option of smoking sections is not recommended under these guidelines.)

(d) Scotland, Smoking, Health and Social Care (Scotland) Act 2005, http://www.opsi.gov.uk/legislation/scotland/acts2005/20050013.htm
Regulations: http://www.opsi.gov.uk/si/si2006/20061115.htm

(e) Uruguay, http://www.globalsmokefreepartnership.org/files/132.doc

(f) Ireland, Public Health (Tobacco) (Amendment) Act 2004, http://193.178.1.79/2004/en/act/pub/0006/index.html

(g) Bermuda, Tobacco Products (Public Health) Amendment Act 2005, http://www.globalsmokefreepartnership.org/files/139.DOC

## ប្រភពឯកសារ


1. WHO policy recommendation on protection from exposure to second-hand tobacco smoke (forthcoming, 2007).

2. Tobacco smoke and involuntary smoking. International Agency for Research on Cancer (IARC) Monograph Vol. 83 (2004). Available at: http://monographs.iarc.fr/ENG/Monographs/vol83/volume83.pdf

3. *The health consequences of involuntary exposure to tobacco smoke: a report of the Surgeon General* (2006). Available at: http://www.surgeongeneral.gov/library/secondhandsmoke/

4. California Environmental Protection Agency (CalEPA) environmental health hazard assessment of environmental tobacco smoke (2005).
Available at:
http://repositories.cdlib.org/tc/surveys/CALEPA2005/ or
http://www.arb.ca.gov/regact/ets2006/ets2006.htm

5. Joint briefing by the Framework Convention Alliance (FCA) and the UICC Global Smokefree Partnership for the meeting to develop guidelines for the implementation of Article 8 of the WHO Framework Convention.
Contact: WHO's Tobacco Free Initiative (TFI) at tfi@who.int for a copy.

6. A resource on smoke-free success stories and challenges. This link includes perspectives on smoke-free policies, links to evaluation reports, legislation and public information campaigns, as well as implementation guidelines.
Available at: www.globalsmokefreepartnership.org

7. After the smoke has cleared: evaluation of the impact of a new smoke-free law. New Zealand, December 2006.
Available at:
http://www.moh.govt.nz/moh.nsf/by+unid/A9D3734516F6757ECC25723D00752D50?Open